ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.333.......សហវ-ប្រក

# ប្រកាស

## ស្តីពីការតែងតាំងវរជ្ញេយ្យករបុរេប្រទាន និងវរជ្ញេយ្យករបុរេប្រទានរង នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/សន/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាន ការតម្លើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល មានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការតម្លើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ឲ្យទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៨ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

<u>**សម្រេច**</u>

**ប្រការ១.**_

ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវត្តថវិកាកម្មវិធីដូចខាងក្រោមៈ

**ក- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

១- លោកស្រី ខ្លូត ម៉ាលី អនុប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ជារដ្ឋទេយ្យករបុរេប្រទាននៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២- លោកស្រី កែវ ផល្លី អនុប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ជារដ្ឋទេយ្យករបុរេប្រទានរងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៣- លោកស្រី សម សុទ្ធារី អនុប្រធានការិយាល័យហិរញ្ញកិច្ច ជារដ្ឋទេយ្យករបុរេប្រទានរងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ខ- អង្គភាពថវិកា និងអង្គភាពអមទីស្តីការក្រសួង**

១- លោក ទី សុង អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ ជារដ្ឋទេយ្យករបុរេប្រទានរងនៃអគ្គនាយកដ្ឋានកសិកម្ម

២- លោក ព្រាក់ សម្បត្តិ អនុប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ ជារដ្ឋទេយ្យករបុរេប្រទានរងនៃអគ្គនាយកដ្ឋានកសិកម្ម

៣- លោក ទឹម ស៊ីថុន អនុប្រធានទទួលបន្ទុកស្តីទីការិយាល័យគណនេយ្យ ហិរញ្ញវត្ថុ ជារដ្ឋទេយ្យករបុរេប្រទានរងនៃអគ្គនាយកដ្ឋានកៅស៊ូ

៤- លោកស្រី ទីវ រ៉ាវី អនុប្រធានការិយាល័យគណនេយ្យ ហិរញ្ញវត្ថុ ជារដ្ឋទេយ្យករបុរេប្រទានរងនៃអគ្គនាយកដ្ឋានកៅស៊ូ

៥- លោក ទូច ប៊ុនធៀង ប្រធានការិយាល័យផែនការ គណនេយ្យ ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានកសិ-ឧស្សាហកម្ម

៦- លោកស្រី ហូ បុប្ផា មន្ត្រីការិយាល័យផែនការ គណនេយ្យ ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានកសិ-ឧស្សាហកម្ម

៧- លោកស្រី សុជាត នារីរត្នន៍ ប្រធានការិយាល័យផែនការ គណនេយ្យ ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល

៨- លោកស្រី ទឹម យូធាវត្តី មន្ត្រីការិយាល័យផែនការ គណនេយ្យ ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល

៩- លោកស្រី ថៃ ស៊ីលាទីណា ប្រធានការិយាល័យគណនេយ្យ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ជារដ្ឋទេយ្យករបុរេប្រទានរងនៃរដ្ឋបាលព្រៃឈើ

១០- លោកស្រី ជិន មករា មន្ត្រីការិយាល័យ គណនេយ្យ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ជារដ្ឋទេយ្យករបុរេប្រទានរងនៃរដ្ឋបាលព្រៃឈើ

១១- លោកស្រី គឹម ណាវី មន្ត្រីការិយាល័យ គណនេយ្យ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ជារដ្ឋទេយ្យករបុរេប្រទានរងនៃរដ្ឋបាលព្រៃឈើ

១២- លោកស្រី ឌុច សុធារី អនុប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ ជារដ្ឋទេយ្យករបុរេប្រទានរងនៃរដ្ឋបាលជលផល

១៣- លោក ភួង ចិត្រា មន្ត្រីនាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ ជារដ្ឋទេយ្យករបុរេប្រទានរងនៃរដ្ឋបាលជលផល

១៤- លោក ឈុប ថាវិត មន្ត្រីការិយាល័យផែនការ ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានផែនការនិងស្ថិតិ

១៥- លោក យាង ប្រណិត មន្ត្រីការិយាល័យសម្របសម្រួលតាមដាននិងវាយតម្លៃគម្រោង ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានផែនការ និងស្ថិតិ

១៦- លោកស្រី ស៊ឹង សុធារី អនុប្រធានការិយាល័យហិរញ្ញកិច្ច ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ

១៧- លោក ម៉ៅ លក្ខិណា អនុប្រធានការិយាល័យលទ្ធកម្មសាធារណៈ ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ

១៨- លោក ឈូរ ឈុនហួរ អនុប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

១៩- លោកស្រី ណាវ៉េត ដានីណា ប្រធានការិយាល័យរដ្ឋបាល ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

២០- លោក លឹម មី អនុប្រធានការិយាល័យរដ្ឋបាលនិងបុគ្គលិក ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

២១- លោកស្រី ឡុង ឡាឌីន មន្ត្រីការិយាល័យរដ្ឋបាលនិងបុគ្គលិក ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

២២- លោក នៅ កុម្ភៈ ប្រធានការិយាល័យអាស៊ានកសិកម្ម ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

២៣- លោកស្រី សារ សុភីរៈ ប្រធានការិយាល័យការងារអង្គការអន្តរជាតិ ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

២៤- លោក ឯម ពិសី អនុប្រធានការិយាល័យរដ្ឋបាលនិងបុគ្គលិក ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋាននីតិកម្មកសិកម្ម

២៥- កញ្ញា វិនីន ម៉ារីណែត មន្ត្រីនាយកដ្ឋាននីតិកម្មកសិកម្ម ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋាននីតិកម្មកសិកម្ម

២៦- លោកស្រី ភួង ចិន្តា អនុប្រធានការិយាល័យផ្គត់ផ្គង់ ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានកិច្ចការរដ្ឋបាល

២៧- លោក ខោល សុជាណា អនុប្រធានការិយាល័យផ្គត់ផ្គង់ ជារដ្ឋទេយ្យករបុរេប្រទានរងនៃនាយកដ្ឋានកិច្ចការរដ្ឋបាល

២៨- លោក សេង ស៊ីនហ៊ាត ប្រធានការិយាល័យរដ្ឋបាល ជារដ្ឋទេយ្យករបុរេប្រទានរងនៃអគ្គាធិការដ្ឋាន

២៩- លោកស្រី សែន ប៉ូរ៉ុង មន្ត្រីនៃអគ្គាធិការដ្ឋាន ជារដ្ឋទេយ្យករបុរេប្រទានរងនៃអគ្គាធិការដ្ឋាន

៣០- កញ្ញា សាយ វ៉ាន់ដែន ប្រធានការិយាល័យរដ្ឋបាលផែនការនិងសហប្រតិបត្តិការអន្តរជាតិ ជារដ្ឋទេយ្យករបុរេប្រទានរងនៃមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

៣១- លោកស្រី ចាន់ មិនា អនុប្រធានការិយាល័យរដ្ឋបាល ផែនការ និងសហប្រតិបត្តិការអន្តរជាតិ ជារដ្ឋទេយ្យករបុរេប្រទានរងនៃមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

**ប្រការ២._**

រដ្ឋទេយ្យករបុរេប្រទានរងតាមបណ្តាអង្គភាពខាងលើមានភារៈកិច្ចដូចខាងក្រោម៖

- ជាអ្នកទទួលថវិកាពីរដ្ឋទេយ្យករបុរេប្រទានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានសិទ្ធិបើកគណនីរដ្ឋទេយ្យបុរេប្រទាននៅធនាគារ

- ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ និងប្រាក់កាសចំពោះការទុកដាក់ថែរក្សានូវមូលនិធិ ដែលខ្លួនបានទទួលចំណាយ និងទុកដាក់ ថែរក្សាលិខិតយុត្តិការព្រមទាំងកាន់កាប់បញ្ជី

គណនេយ្យនៃកិច្ចប្រតិបត្តិការ

- រជ្ជទេយ្យករបុរេប្រទានរងរបស់អង្គភាពថវិកា និងអង្គភាពថវិកា និងអង្គភាពអមទីស្តីការក្រសួងត្រូវប្រមូលលិខិតយុត្តិការចំណាយជូនមករជ្ជទេយ្យករបុរេប្រទានក្រសួង ដើម្បីធ្វើការទូទាត់ជម្រះបញ្ជីរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤._**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរ ក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១១ខែមិថុនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត អ៊ុក រ៉ាប៊ុន

<u>កន្លែងទទួល៖</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមុខងារសាធារណៈ

-អគ្គលេខាធិការ រាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-សាលារាជធានី ខេត្ត

-ដូចប្រការ៤

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ